ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គម្រោងដាំដំណាំសាលាដ ក្នុងផ្ទះសំណាញ់





# សេចក្តីសង្ខេបនៃគម្រោង

**១-ទីតាំងកសិករដាំ** ÷ នៅភូមិពោធិព្រះសង្ឃ ឃុំតាភាម ស្រុកត្រាំកក់ ខេត្តតាកែវ
**២-គម្រោង** ÷ ដំណាំសាលាដ ក្នុងផ្ទះសំណាញ់
**៣-ទំហំសំណាញ់** ÷ ២៤០ម៉ែត្រការ៉េ ( ១០ម x ២៤ម = ២៤០ម$^{២}$ )
**៤-ទំហំរង** ÷ ទទឹង១ម x បណ្តោយ២៣ម ដោយទុកគម្លាត ០,៥ម ចុងនិងដើមរង
**៥-ចំនួនរង** ÷ ធ្វើបាន៨រង ដោយរក្សាគម្លាត០,២២មពីរង១ទៅរង១
**៦-ការសាបបណ្តុះកូន** ÷ បណ្តុះកូនអាយុចាប់ពី១៥ថ្ងៃ ទើបយកទៅដាំបាន
**៧-រយៈពេលដាំ** ÷ ដាំចាប់ពី២៥ថ្ងៃទៅ៣០ថ្ងៃ ចាប់ផ្តើមប្រមូលផល
**៨-ចំនួនថ្ងៃ / វដ្ត** ÷ ពី ៣២ថ្ងៃ ទៅ ៣៨ថ្ងៃ (ទុកចន្លោះពេលហាលដី ៧ថ្ងៃ )
**៩-ក្រោយពីប្រមូលផល** ÷ ត្រូវសម្អាតដី ហាលដីចំនួន៧ថ្ងៃ និងដាំប្រភេទបន្លែខុសពីការដាំមុន
**១០-រដូវកាលដាំដុះ** ÷ អាចដាំបានពេញ១ឆ្នាំ អាស្រ័យដោយមានប្រភពទឹកគ្រប់គ្រាន់
(បើដាំគ្រាប់១ឆ្នាំដាំបាន៦វដ្ត បើដាំកូនដាំបាន៨វដ្ត)
**១១-ទិន្នផលក្នុង១រង** ÷ (ជាមធ្យម ២,២គក្រ / ម$^{២}$ ) → ២,២គក្រ x២៣ម$^{២}$= ៥០,៦គក្រ
**ទិន្នផលក្នុង៨រង**÷ ៥០,៦គក្រ x ៨ = ៤០៤,៨គក្រ (ស្រកស្រុត ៥%) = ៣៨៤,៥៦គក
**១២-ទីផ្សារ** ÷ ឈ្មួញចុះទិញដល់ចម្ការ ឬដឹកមកបោះដុំនៅផ្សារ
**១៣-តម្លៃ** ÷ ពី ៤,០០០-៦,០០០រៀល/គ.ក្រ តម្លៃជាមធ្យម ៥,០០០រៀល/គ.ក្រ
(តម្លៃក្នុងខែមករា ឆ្នាំ២០២២)
**១៤-តម្រូវការទុន** ÷ ការដាំសាលាដក្នុងផ្ទះសំណាញ់លើផ្ទៃដីទំហំ **២៤០ម៉ែត្រការ៉េ** ត្រូវការដើមទុនចំនួន **11,705,200 រៀល** (មានដីផ្ទាល់ខ្លួន និងទិញផ្ទះសំណាញ់)រួមមាន÷

| ចំណាយវិនិយោគលើការរៀបចំប្រព័ន្ធស្រោចស្រព | ចំណាយយលើការដាំដុះនិងថែទាំ | ចំណាយសរុប |
|---|---|---|
| 11,124,200 រៀល | 581,000 រៀល | 11,705,200 រៀល |

**១៥-ការវិភាគសេដ្ឋកិច្ចលើការដាំសាលាដ លើផ្ទៃដី២៤០ម៉ែត្រការ៉េ/វដ្ត ÷**

| ចំណាយ | ចំណូល | ចំណេញ | ថ្លៃដើម/គ.ក | ចំណេញ/គ.ក |
|---|---|---|---|---|
| 868,841 រៀល | 1,920,000 រៀល | 1,051,159 រៀល | 2,262.61រៀល | 2,737.39រៀល |

## ១៦-ចំណូល-ចំណាយលើការដាំសាលាដក្នុងផ្ទះសំណាញ់លើផ្ទៃដី ២៤០ម៉ែ² ក្នុង១វដ្ត រយៈពេលពី២៤ ទៅ ៣០ថ្ងៃ

| បរិយាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ/ឯកត្តា (រៀល) | ទឹកប្រាក់ (រៀល) | ចំនួនសាររំលោះ | ទឹកប្រាក់សរុប (រៀល) |
|---|---|---|---|---|---|---|
| **១-ចំណូលពីការលក់សាលាដ** | គ.ក | 384 | 5,000 | 1,920,000 | | **1,920,000** |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល** | | | | | | **868,841** |
| **២.ក-ចំណាយប្រែប្រួលសរុប** | | | | | | **581,000** |
| ផ្ទៃដី+ ពូនរង | សារ | 1 | 100,000 | 100,000 | | 100,000 |
| កំបោរសម្លាប់មេរោគ | គ.ក | 15 | 2,000 | 30,000 | | 30,000 |
| ចំណាយលើការបណ្ដុះកូន | សារ | 1 | 50,000 | 50,000 | | 50,000 |
| ពូជ | កញ្ចប់ | 1 | 5,000 | 5,000 | | 5,000 |
| ជីកសិកម្ម | គ.ក | 6.25 | 1,600 | 10,000 | | 10,000 |
| ជីទ្រាប់បាត ( លាមកគោ+ លាមកទា) | បាវ | 24 | 4,000 | 96,000 | | 96,000 |
| ថ្នាំសម្លាប់សត្វល្អិត និងការពារជម្ងឺ | វដ្ត | 1 | 20,000 | 20,000 | | 20,000 |
| ថ្លៃអគ្គិសនីបូមទឹកស្រោចស្រព | វដ្ត | 1 | 50,000 | 50,000 | | 50,000 |
| ពលកម្មមើលថែទាំ | វដ្ត | 1 | 100,000 | 100,000 | | 100,000 |
| សម្ភារៈវេចខ្ចប់ | វដ្ត | 1 | 20,000 | 20,000 | | 20,000 |
| សេវាប្រមូលផល+ ដឹកជញ្ជូន | វដ្ត | 1 | 100,000 | 100,000 | | 100,000 |
| **២.ខ-ចំណាយមិនប្រែប្រួលសរុប** | | | | **11,124,200** | | **287,841** |
| ម៉ូទ័របូមទឹក ( ប្រើបាន៥ឆ្នាំ, ១ឆ្នាំ= ៨វដ្ត) | គ្រឿង | 1 | 660,000 | 660,000 | 40 | 16,500 |
| ខ្សែភ្លើង | ដុំ | 1 | 80,000 | 80,000 | 40 | 2,000 |
| ទុយោមេ | ដើម | 10 | 20,000 | 200,000 | 40 | 5,000 |
| ទុយោជ័រតំណក់ទឹក | ដុំ | 1 | 115,000 | 115,000 | 24 | 4,792 |
| ទុយោជ័រសាច | ដុំ | 1 | 45,000 | 45,000 | 24 | 1,875 |
| រ៉ូប៊ីណេតំណក់ទឹក | គ្រាប់ | 32 | 600 | 19,200 | 24 | 800 |
| ទុយោកែង + តេ | គ្រាប់ | 9 | 3,000 | 27,000 | 24 | 1,125 |
| រ៉ូប៊ីណេធំ | គ្រាប់ | 5 | 10,000 | 50,000 | 24 | 2,083 |
| ហ្វីត | គ្រាប់ | 32 | 4,000 | 128,000 | 24 | 5,333 |
| ត្រេបណ្ដុះកូន | បន្ទះ | 50 | 4,000 | 200,000 | 24 | 8,333 |

| | | | | | | |
|---|---|---|---|---|---|---|
| ផ្ទះសំណាញ់ 10m x 24m=$240^2$ (ប្រើបាន៥ឆ្នាំ ១ឆ្នាំ = ៨វគ្គ | ម២ | 240 | 40,000 | 9,600,000 | 40 | 240,000 |
| **៣-ចំណេញសរុប** | | | | | | **1,051,159** |

## ១៧- លទ្ធភាពចំណេញដោយផ្អែកលើនិន្នាការតម្លៃ÷

-តម្លៃទាបបំផុត÷ ៤,០០០រៀល/គ.ក្រ

-តម្លៃខ្ពស់បំផុត÷ ៦,០០០រៀល/គ.ក្រ

| ករណី | ទិន្នផល គ.ក | តម្លៃ រៀល/គ.ក | ចំណូល រៀល | ចំណាយ រៀល | ចំណេញ | |
|---|---|---|---|---|---|---|
| | | | | | រៀល | % |
| ករណីទី១ | 384 | 4,000 | 1,536,000 | 868,841 | 667,159 | 77% |
| ករណីទី២ | 384 | 4,500 | 1,728,000 | 868,841 | 859,159 | 99% |
| ករណីទី៣ | 384 | 5,000 | 1,920,000 | 868,841 | 1,051,159 | 121% |
| ករណីទី៤ | 384 | 5,500 | 2,112,000 | 868,841 | 1,243,159 | 143% |
| ករណីទី៥ | 384 | 6,000 | 2,304,000 | 868,841 | 1,435,159 | 165% |

## ១៨-តម្រូវការចំនួនផ្ទះសំណាញ់សម្រាប់ការដាំដុះវិលជុំដើម្បីទទួលបានចំណូល ៦,០០០ ដុល្លារ/ថ្ងៃ

| ករណី | លទ្ធផលជាក់ស្តែងក្នុង១ផ្ទះសំណាញ់ | | | ផែនការ | | |
|---|---|---|---|---|---|---|
| ផ្អែកតាមតម្លៃលក់/គ.ក | ទិន្នផលជាមធ្យម គ.ក/ផ្ទះ | តម្លៃ រៀល/គ.ក | ចំណូលពីការលក់សរុប | ចំណូលពីការលក់ឱ្យបាន 6,000$ =24,000,000៛ | តម្រូវការផ្ទះសំណាញ់ដាំដុះ/វគ្គ | តម្រូវការផ្ទះសំណាញ់ដាំដុះវិលជុំ |
| A | B | C | D=B*C | E | F=E/D | G=F*38[1] |
| ករណីទី១ | 384 | 4,000 | 1,536,000 | 24,000,000 | 16 | 594 |
| ករណីទី២ | 384 | 4,500 | 1,728,000 | 24,000,000 | 14 | 528 |
| ករណីទី៣ | 384 | 5,000 | 1,920,000 | 24,000,000 | 13 | 475 |
| ករណីទី៤ | 384 | 5,500 | 2,112,000 | 24,000,000 | 11 | 432 |
| ករណីទី៥ | 384 | 6,000 | 2,304,000 | 24,000,000 | 10 | 396 |

[1]-**រយៈពេលដាំក្នុង១វគ្គ = ៣៨ថ្ងៃ**

## ១៩-បច្ចេកទេសដាំដុះ

### ក/. ការជ្រើសរើសពូជ ត្រៀមពូជសាប និងសាបគ្រាប់ ÷

ត្រូវជ្រើសរើសពូជដែលមានប្រវត្តិច្បាស់លាស់ ជាគ្រាប់ពូជដែលមានដំណុះចាប់ពី៨០% ឡើងទៅ ពូជល្អត លាស់រយៈពេលខ្លីស្របនឹងតំបន់ដាំដុះ។ ក្នុងការត្រៀមពូជសាប ត្រូវយកគ្រាប់ទៅខ្ចប់ក្រណាត់ដែលងាយជក់ទឹក ហើយត្រាំទុក ១យប់ ដើម្បីឱ្យគ្រាប់ស្រូបយកទឹកឆាប់ដុះពន្លក។ នៅលើរងសាប ត្រូវរៀបចំដោយដាក់ជីកំប៉ុស្តទ្រាប់បាត។ ក្រោយពីសាបគ្រាប់ហើយ ត្រូវកាប់ចិញ្ច្រាំកំទេចចំបើងគ្របពីលើ ការពារការខ្ទាតគ្រាប់នៅពេលស្រោចទឹក និងជួយថែរក្សាសំណើម។

ចំពោះការថែទាំក្នុងពេលសាបត្រូវស្រោចទឹកមួយថ្ងៃ ២ដង នៅរដូវប្រាំង និងដករំលោះកូនចេញខ្លះនៅកន្លែងដែលដុះញឹកពេក។ រក្សាទុកដើមដែលថ្លោសល្អសំរាប់យកទៅស្ទូងលើរង។ ក្រោយពីសាបគ្រាប់បានរយៈពេលពី ១០-១៥ថ្ងៃ ត្រូវដកកូនសាលាដយកទៅដាំនៅលើរង។

### ខ/. ការរៀបចំដី ÷

ភ្ជួរឬកាប់ដីជម្រៅ ២ -២,៥តឹក ហាលដី៧ថ្ងៃ ទទឹងរង ១ម៉ែត្រ បណ្តោយរងតាមចំណង់ចង់បានឬតាមស្ថានភាពដីក្នុងផ្ទះសំណាញ់ កម្ពស់រង ១ - ១,៥ តឹក ចន្លោះរង ២,៥ -៣ តឹកនិងនៅលើរងនីមួយៗ ត្រូវដាក់ជីលាមកគោពុកផុយ បន្ទាប់មកជ្រុំដីបញ្ចូលទៅក្នុងដីឱ្យសព្វ រួចទុករយៈពេល ៣ថ្ងៃ ទើបយកកូនមកដាំ។

### គ/. ការដាំនិងថែទាំ

នៅពេលកូនសាលាដមានអាយុ ១០-១៥ ថ្ងៃ យើងអាចដកយកវាទៅដាំបានហើយ តែមុននឹងដកត្រូវបន្ថយការស្រោចទឹកពី ២-៣ថ្ងៃ ដើម្បីឱ្យដើមវារឹង និងដកកូនណាដែលមានដើមធំស្មើគ្នា ត្រូវស្រោចទឹកលើរងឱ្យជោគល្អមុនពេលដាំ។ ការដាំត្រូវដាក់ឫសមួយជំហរកុំឱ្យច្បត់ឫសឱ្យសោះ ចន្លោះជួរពី ២តឹក និងចន្លោះគុម្ព ១,៥តឹក នឹងត្រូវកាត់ចំបើងខ្លីៗគ្របតាមគល់សាលាដដើម្បីរក្សាសំណើមដីបានល្អ ស្រោចទឹកពី៣ -៤ដង ក្នុងមួយថ្ងៃ ក្រោយពីដាំបាន៣-៤ថ្ងៃដំបូង ។

### ឃ/. ការប្រមូលផល

ការដាំសាលាដក្នុងផ្ទះសំណាញ់ដោយការសាបដកកូនដាំ នឹងអាចប្រមូលផលក្នុងរយៈពេលដាំតែ២៥ថ្ងៃទៅ៣០ថ្ងៃ ក្រោយពីដាំ។

## ២០-ចំណុចខ្លាំង÷

- មានតម្រូវការទីផ្សារ និងអាចលក់បានគ្រប់រដូវ ដោយឈ្មួញចុះមកទិញដល់ចម្ការ
- អាចរកបានប្រាក់ចំណូលសមរម្យ
- មានបទពិសោធន៍ ក្នុងការដាំបន្លែរយៈពេលយូរឆ្នាំ
- មានដីចម្ការផ្ទាល់ខ្លួន មិនជួលដីគេ

- មានទុនផ្ទាល់ខ្លួនសម្រាប់ដាំ
- ប្រភពទឹកមានគ្រប់គ្រាន់ គឺប្រើទឹកត្រពាំងផ្ទាល់ខ្លួនក្បែរចម្ការ
- មិនមានសត្វល្អិត បំផ្លាញដំណាំ ដោយមានផ្ទះសំណាញ់ការពារ
- មិនចាំបាច់ប្រើថ្នាំពុល
- ងាយស្រួលថែទាំ

**២១-ចំណុចខ្សោយ÷**

- ផ្ទះសំណាញ់មានទំហំតូច ដំណាំមានតិច មិនអាចផ្គត់ផ្គង់ដល់តម្រូវការទីផ្សារបានគ្រប់គ្រាន់
- នៅខ្វះបច្ចេកទេសក្នុងការដាំដុះ ដាំបានទិន្នផលតិច
- ការផ្សព្វផ្សាយពីបច្ចេកទេស ដាំដំណាំពីសមត្ថកិច្ចជំនាញនៅមានកម្រិត
- ការស្រោចស្រពដំណាំពេលខ្លះខ្វះទឹកដោយត្រពាំងរីងខែប្រាំង
- តម្លៃប្រេង និងអគ្គិសនីសម្រាប់ប្រើប្រាស់បូមទឹក នៅមានតម្លៃខ្ពស់
- បញ្ហាប្រឈមក្នុងការប្រកួតប្រជែងទីផ្សារកសិផល ពិសេសគឺបន្លែមកពីប្រទេសជិតខាងនិងការធ្លាក់ថ្លៃពេលរដូវប្រមូលផល
- អ្នកហូបភាគច្រើនមិនសូវយល់ពីអត្ថប្រយោជន៍នៃការបរិភោគបន្លែគ្មានជាតិគីមី។

**២២-សេចក្តីសន្និដ្ឋាន÷**

ការដាំបន្លែក្នុងផ្ទះសំណាញ់កសិករអាចជួបនឹងហានិភ័យមួយចំនួន÷

**ក-ហានិភ័យផលិតកម្ម (Production Risks) ÷**

ក.១. ពាក់ព័ន្ធនឹងអាកាសធាតុដែលប្រែប្រួលលឿន ពេលខ្លះសីតុណ្ហភាពឡើងក្តៅខ្លាំងធ្វើឱ្យដំណាំស្វិត ឬក្រៀមត្រួយ ពេលខ្លះសីតុណ្ហភាពត្រជាក់ខ្លាំងធ្វើឱ្យដំណាំរួញត្រួយ មិនលូតលាស់ និងបានបង្កឱ្យជាបញ្ហារលួយ មានសត្វល្អិតបំផ្លាញច្រើន និងមានជម្ងឺរលាកដើមជាហេតុទទួលបានទិន្នផលទាប មិនសមស្របតាមការរំពឹងទុក

ក.២. ការកើតជំងឺ និងសត្វល្អិតចង្រៃបំផ្លាញ ដែលបណ្តាលមកពីខ្វះអនាម័យនៅជុំវិញផ្ទះសំណាញ់ គ្មានវិធានការការពារ មិនមានបច្ចេកទេសច្បាស់លាស់ក្នុងការកំណត់ជម្ងឺ ជឿតែលើអ្នកលក់ថ្នាំ-ជី

ក.៣. ប្រព័ន្ធស្រោចស្រពមិនគ្រប់គ្រាន់ ជាការធ្វើឱ្យដំណាំខូចខាត និងកើនឡើងថ្លៃដើមផលិតកម្ម ដោយចំណាយលើការស្រោចស្រពខ្ពស់។

**ខ-ហានិភ័យទីផ្សារ (Marketing Risks ) ÷**

-លទ្ធភាពនៃការបាត់បង់ទីផ្សារ ឬតម្លៃដែលទទួលបានទាបជាងការរំពឹងទុក។ ការធ្លាក់ចុះការលក់និងតម្លៃដែលបណ្តាលមកពីការកើនឡើងនូវចំនួនអ្នកដាំក្នុងស្រុក ឬការផ្លាស់ប្តូរចំណង់ចំណូលចិត្តអតិថិជន។

-មិនបានបំពេញតាមស្តង់ដារទីផ្សារ ឬតម្រូវការរបស់អ្នកទិញ ដូចជា គុណភាព បរិមាណ តម្លៃនិងការវេចខ្ចប់ឱ្យបានត្រឹមត្រូវ។

-មិនបានតភ្ជាប់ខ្សែច្រវ៉ាក់ផលិតកម្មរវាងអ្នកផលិត ឈ្មួញកណ្តាលប្រមូលទិញ និងអតិថិជនទិញ។

-បន្លែដែលនាំចូលមកពីប្រទេសជិតខាងមានតម្លៃថោក

-រៀបចំប្រតិទិនដាំដុះឱ្យត្រឹមត្រូវ ជៀសវាងជន់នៅលើទីផ្សារ

-ត្រូវរៀបចំផលិតបន្លែឱ្យបានគ្រប់រដូវ ទាំងរដូវវំហើយ រដូវក្តៅ រដូវភ្លៀង។

**គ-ហានិភ័យហិរញ្ញវត្ថុ ( Financial Risks) ÷**

-ការដាំសាលាដក្នុងផ្ទះសំណាញ់ត្រូវការចំណាយដើមទុនច្រើន ដែលកសិករមិនមានថវិកាគ្រប់គ្រាន់ សម្រាប់ការផលិត និងវិនិយោគលើការដាំដុះ ឬត្រៀមបម្រុងសម្រាប់ហេតុការឡើងដោយចៃដន្យ

- កសិករភាគច្រើនបានទទួល ទុនកម្ចីពីធនាគារ ឬគ្រឹស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានការប្រាក់ខ្ពស់ ៕